ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ ធ១៤-០២៣-០៤២ ធ.ក.ស.ព.ព

ថ្ងៃ ចន្ទ ៦ កើត ខែ មិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ២០២៣

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## ពិធីចុះហត្ថលេខាលើអនុស្សរណៈនៃកិច្ចសហប្រតិបត្តិការ ស្តីពី ការទូទាត់ឆ្លងដែនតាមយូអរកូដ រវាងធនាគារជាតិនៃកម្ពុជា និងក្រសួងសេដ្ឋកិច្ច ពាណិជ្ជកម្ម និងឧស្សាហកម្ម នៃប្រទេសជប៉ុន

នៅថ្ងៃចន្ទ ៦កើត ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២៣ លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា និងឯកឧត្តម SAITO Ken រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច ពាណិជ្ជកម្ម និងឧស្សាហកម្ម នៃប្រទេសជប៉ុន បានអញ្ជើញចុះហត្ថលេខាលើអនុស្សរណៈ នៃកិច្ចសហប្រតិបត្តិការ ស្តីពី ការទូទាត់ឆ្លងដែនតាមយូអរកូដ (Unified QR Code-Based Payment) ។

ពិធីចុះហត្ថលេខាលើអនុស្សរណៈនៃកិច្ចសហប្រតិបត្តិការនេះ រៀបចំឡើងក្រោមសហអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងឯកឧត្តម **KISHIDA Fumio** នាយករដ្ឋមន្ត្រី នៃប្រទេសជប៉ុន នៅក្នុងកិច្ចប្រជុំកំពូលកម្ពុជា-ជប៉ុន ដែលបានប្រព្រឹត្តទៅនៅទីក្រុងតូក្យូ ប្រទេសជប៉ុន ពីថ្ងៃទី១៦ ដល់ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២៣។

អនុស្សរណៈនៃកិច្ចសហប្រតិបត្តិការនេះ រៀបចំឡើងក្នុងគោលបំណងកំណត់ក្របខណ្ឌជាក់លាក់ សម្រាប់កិច្ចសហប្រតិបត្តិការលើកកម្ពស់សកម្មភាពប្រើប្រាស់ប្រព័ន្ធទូទាត់ឆ្លងដែនតាមយូអរកូដ (QR Code) ដ៏ងាយស្រួល មានសុវត្ថិភាព និងប្រសិទ្ធភាព។ ក្របខណ្ឌកិច្ចសហប្រតិបត្តិការនេះក៏នឹងជួយបង្កើន ចរាចររូបិយវត្ថុជាតិ ព្រមទាំងជំរុញវិស័យទេសចរណ៍រវាងប្រទេសទាំងពីរឱ្យកាន់តែមានសក្តានុពល ថែមទៀតផងដែរ។/

**ទំនាក់ទំនង ៖**
ផ្នែកទំនាក់ទំនង ធនាគារជាតិនៃកម្ពុជា
ទូរស័ព្ទ ៖ (៨៥៥) ២៣ ៩៩០ ១៩៧
អ៊ីម៉ែល ៖ nbccommunication@nbc.gov.kh
**បណ្តាញសារព័ត៌មានផ្លូវការរបស់ធនាគារជាតិនៃកម្ពុជា ៖**
www.nbc.gov.kh, www.facebook.com/nationalbankofcambodiaofficial , www.twitter.com/nbccambodia , www.instagram.com/nationalbankofcambodia , www.linkedin.com/company/national-bank-of-cambodia , www.youtube.com/channel/UC3GoCm_QGSSLjXZXvbcATfA